ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# បទបង្ហាញអំពី
# ការអនុវត្តកិច្ចសន្យាការងារ និងអត្ថប្រយោជន៍ ដែលទទួលបាន ក្រោយរំលាយកិច្ចសន្យាការងារ

ដោយ ៖ **លោក ទង់ ពេជ្ររតនៈ** | ប្រធានការិយាល័យ នៃនាយកដ្ឋានអធិការកិច្ចការងារ

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ | រាជធានីភ្នំពេញ ត្រូវនឹងថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៥
ភោជនីយដ្ឋានទន្លេបាសាក់២

# មាតិកា

## I. សេចក្ដីផ្ដើម

ក. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ខ. ដែនអនុវត្តច្បាប់ស្ដីពីការងារ

## II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយកិច្ចសន្យាការងារ

ក. និយមន័យ និងការបង្កើតកិច្ចសន្យាការងារ

ខ. កិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC)

គ. កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC)

# I. សេចក្តីផ្តើម

## ក. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

១. ព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

២. ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១០ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីវិសោធកម្មមាត្រា៨៧ ចំណងជើងចំណុច (គ) ផ្នែកទី៣ នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០៩/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧

៣. ប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

៤. សេចក្តីណែនាំលេខ ០៥៨/១៩ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារថ្មីនីមួយៗចាប់ពីឆ្នាំ២០១៩

៥. សេចក្តីណែនាំលេខ ០៥០/១៩ ក.ប/ស.ណ.ន.គ.ប.ក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការកំណត់ប្រភេទកិច្ចសន្យាការងារ

៦. សេចក្តីជូនដំណឹង ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ ស្តីពីអត្ថប្រយោជន៍ដែលទទួលបាន ក្រោយរំលាយកិច្ចសន្យាការងារ

# I. សេចក្តីផ្តើម

## ខ. ដែនអនុវត្តច្បាប់ស្តីពីការងារ យោងមាត្រា ១ នៃច្បាប់ស្តីពីការងារ



- ច្បាប់ស្តីពីការងារគ្រប់គ្រងរាល់ទំនាក់ទំនង ដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិតដើម្បីយកមកអនុវត្តលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយ ទោះបីភាគីទាំងនោះមានសញ្ជាតិជាអ្វី ហើយស្នាក់នៅទីណាក៏ដោយ។



- ច្បាប់នេះអនុវត្តចំពោះសហគ្រាស ឬគ្រឹះស្ថានឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវាកសិកម្ម ដឹកជញ្ជូនតាមផ្លូវ គោកឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនា ក៏ដោយទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬជាការកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវៈសេរីនៃ សមាគម ឬនៃក្រុមប្រភេទណាក៏ដោយ ។

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## ក. និយមន័យ និងការបង្កើតកិច្ចសន្យាការងារ យោងមាត្រា ៦៥ នៃច្បាប់ស្តីពីការងារ

- ❖ កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងារ រវាងកម្មករនិយោជិត និងនិយោជក។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទម្រង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា។



លាយលក្ខណ៍អក្សរ

- ❖ កិច្ចសន្យានេះអាចធ្វើជា លាយលក្ខណ៍អក្សរ ឬដោយមាត់ទទេ។ ...



ផ្ទាល់មាត់

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## *** កិច្ចសន្យាសាកល្បងការងារ

- ជារយៈពេលនិយោជក វិនិច្ឆ័យសមត្ថភាព ជំនាញ ទេពកោសល្យ និងឆន្ទៈ
- ជារយៈពេលកម្មករនិយោជិត ស្គាល់យ៉ាងជាក់លាក់អំពីលក្ខខណ្ឌការងារ
- ការចុះកិច្ចសន្យាសាកល្បងការងារមិនអាចមានថិរវេលាលើសពី៖
  - ៣ ខែ ចំពោះនិយោជិត
  - ២ ខែ ចំពោះកម្មករឯកទេស
  - ១ ខែ ចំពោះកម្មករធម្មតា
- មិនបាច់គោរពកាតព្វកិច្ចឱ្យដំណឹងមុន




ច្បាប់ស្តីពីការងារ៖ មាត្រា៦៨ និងមាត្រា៨២

សេចក្តីណែនាំលេខ០៥០/១៩

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## ខ. កិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC)

### ១. លក្ខខណ្ឌនៃការបង្កើត និងទម្រង់

- ត្រូវធ្វើជាលាយលក្ខណ៍អក្សរ
- មានកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ច្បាស់លាស់
- កិច្ចសន្យាការងារនេះមិនចាំបាច់មានកាលបរិច្ឆេទបញ្ចប់ច្បាស់លាស់ ប្រសិនបើ៖
  - ជួលកម្មករនិយោជិតម្នាក់ដើម្បីជំនួសកម្មករនិយោជិតម្នាក់ទៀតដែលមានជំងឺ
  - ជួលកម្មករនិយោជិតម្នាក់សម្រាប់ការងារតាមរដូវ
  - ជួលកម្មករនិយោជិតម្នាក់សម្រាប់ការងារដែលច្រើនខុសប្រក្រតី
- មានថិរវេលាមិនលើសពី ២ ឆ្នាំ
- អាចបន្តសារជាថ្មីម្តង ឬច្រើនដងបានដរាបណាថិរវេលាអតិបរមាមិនលើសពី ២ឆ្នាំ

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## ខ. កិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC)

### ១. លក្ខខណ្ឌនៃការបង្កើត និងទម្រង់ (ត)



# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## ខ. កិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC)

### ២. ការរំលាយកិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC)

- ការរំលាយកិច្ចសន្យាមុនកាលកំណត់
  - មានការព្រមព្រៀងគ្នាពីភាគីនិយោជក និងកម្មករនិយោជិត ឬ
  - ដោយសារកំហុសធ្ងន់របស់ភាគីកម្មករនិយោជិត ឬ
  - ដោយសារករណីប្រធានសក្តិ
- ថិរវេលានៃការជូនដំណឹងមុនកាលកំណត់នៃកិច្ចសន្យា
  - ចំពោះកិច្ចសន្យាដែលមានថិរវេលាលើសពី ៦ខែ កម្មករនិយោជិតត្រូវបានគេជូនដំណឹងជាមុន ១០ ថ្ងៃ
  - ចំពោះកិច្ចសន្យាដែលមានថិរវេលាលើសពី ១ឆ្នាំ កម្មករនិយោជិតត្រូវបានគេជូនដំណឹងជាមុន ១៥ ថ្ងៃ

*** *បើគ្មានការជូនដំណឹងមុនទេ កិច្ចសន្យាត្រូវបន្តក្នុងថិរវេលាស្មើគ្នានឹងថិរវេលាដែលបានចុះកិច្ចសន្យាគ្រាដំបូង ឬត្រូវចាត់ទុកថាជាកិច្ចសន្យាគ្មានកំណត់*

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## ខ. កិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC)

### ៣. អត្ថប្រយោជន៍ដែលទទួលបានក្រោយការរំលាយកិច្ចសន្យាការងារ FDC

ដល់កាលកំណត់៖ ការរំលាយកិច្ចសន្យាដោយនិយោជកស្របតាមច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)
- ❖ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥%នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា (មាត្រា៧៣)

១

ដល់កាលកំណត់៖ ការរំលាយកិច្ចសន្យាដោយកម្មករនិយោជិតស្របតាមច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាចទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)
- ❖ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥%នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា (មាត្រា៧៣)

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## ខ. កិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC)

### ៣. អត្ថប្រយោជន៍ដែលទទួលបានក្រោយការរំលាយកិច្ចសន្យាការងារ FDC

មុនកាលកំណត់៖ ការរំលាយកិច្ចសន្យាដោយដោយនិយោជកស្របតាមច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)
- ❖ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥%នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា (មាត្រា៧៣)

២

មុនកាលកំណត់៖ ការរំលាយកិច្ចសន្យាដោយដោយកម្មករនិយោជិតស្របតាមច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## ខ. កិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC)

### ៣. អត្ថប្រយោជន៍ដែលទទួលបានក្រោយការរំលាយកិច្ចសន្យាការងារ FDC

ដោយកំហុសធ្ងន់របស់កម្មករនិយោជិត៖ ការរំលាយកិច្ចសន្យាដោយដោយនិយោជកស្របតាមច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)

៣

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## ខ. កិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC)

### ៣. អត្ថប្រយោជន៍ដែលទទួលបានក្រោយការរំលាយកិច្ចសន្យាការងារ FDC

ការរំលាយកិច្ចសន្យាដោយឆន្ទៈរបស់និយោជកតែឯកឯងមុនកាលកំណត់ ក្រៅពីមូលហេតុមានចែងក្នុងច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)
- ❖ ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥%នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យា (មាត្រា៧៣)
- ❖ ជំងឺចិត្ត ស្មើប្រាក់ឈ្នួល ដែលកម្មករនិយោជិតត្រូវទទួលបានរហូតដល់ពេលចប់កិច្ចសន្យា

៤

ការរំលាយកិច្ចសន្យាដោយឆន្ទៈរបស់កម្មករនិយោជិតតែឯកឯងមុនកាលកំណត់ ក្រៅពីមូលហេតុមានចែងក្នុងច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## គ. កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC)

### ១. លក្ខខណ្ឌនៃការបង្កើត និងទម្រង់

- អាចធ្វើជាលាយលក្ខណ៍អក្សរ ឬធ្វើផ្ទាល់មាត់ក៏បាន
- មានពេលវេលាចាប់ផ្ដើម ប៉ុន្តែមិនមានពេលកំណត់បញ្ចប់

### ២. ការរំលាយកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) - ទូទៅ

- អាចរំលាយតាមឆន្ទៈភាគីតែម្ខាងបាន ដោយត្រូវអនុវត្តទៅតាមរបៀបឱ្យដំណឹងមុនជាលាយលក្ខណ៍អក្សរដែលភាគីមានបំណងចង់រំលាយកិច្ចសន្យាត្រូវឱ្យទៅភាគីម្ខាងទៀត
- គ្មានការបញ្ឈប់ណាមួយអាចធ្វើទៅបានដោយគ្មានហេតុផលសមរម្យទាក់ទងនឹងអត្តចរិត ឬសម្បទារបស់កម្មករនិយោជិត យោងទៅលើភាពចាំបាច់នៃដំណើរការរបស់សហគ្រាស គ្រឹះស្ថាន ឬរបស់ក្រុមឡើយ។

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## ៣. ចិរវេលាដែលត្រូវឱ្យដំណឹងមុនត្រូវកំណត់ជាអប្បបរមាដូចខាងក្រោម៖

| អតីភាពការងារ | ចិរវេលា នៃការជូនដំណឹង |
|---|---|
| តិចជាង ៦ខែ | ៧ថ្ងៃ |
| ចាប់ពី ៦ខែ រហូតដល់ ២ឆ្នាំ | ១៥ថ្ងៃ |
| លើសពី ២ឆ្នាំ ដល់ ៥ឆ្នាំ | ១ខែ |
| លើសពី ៥ឆ្នាំ ដល់ ១០ឆ្នាំ | ២ខែ |
| លើសពី ១០ឆ្នាំ | ៣ខែ |

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## គ. កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC)

### ២. ការរំលាយកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) - ការបញ្ឈប់ពីការងាររួម (មាត្រា៩៥)

ការបញ្ឈប់ការងារដោយមកពីការបន្ថយសកម្មភាពនៃគ្រឹះស្ថាន ឬមកពីការរៀបចំផ្ទៃក្នុង

- ❖ លំដាប់នៃការបញ្ឈប់ ទៅតាមគុណសម្បត្តិនៃវិជ្ជាជីវៈ អតីតភាពក្នុងគ្រឹះស្ថាន និងបន្ទុកគ្រួសារនៃកម្មករនិយោជិត
- ❖ អនុវត្តនីតិវិធីបញ្ចប់កិច្ចសន្យាការងារ និងទូទាត់អត្ថប្រយោជន៍ យោងលើប្រភេទនៃកិច្ចសន្យាការងារនីមួយៗ
- ❖ ផ្តល់ជូនអធិការការងារនូវព័ត៌មានអំពីនីតិវិធីដែលមានចែងក្នុងមាត្រា ៩៥
- ❖ ឱ្យដំណឹងជាលាយលក្ខណ៍អក្សរទៅតំណាងកម្មករនិយោជិត

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## គ. កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC)

### ៣. អត្ថប្រយោជន៍ដែលទទួលបានក្រោយការរំលាយកិច្ចសន្យាការងារ UDC

មានហេតុផលសមរម្យ និងមានការជូនដំណឹងមុនត្រឹមត្រូវ៖ការរំលាយកិច្ចសន្យាដោយដោយនិយោជកស្របតាមច្បាប់

- ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)
- ប្រាក់បំណាច់អតីតភាពការងារ (មាត្រា៨៩ថ្មី)

១

មានហេតុផលសមរម្យ និងមានការជូនដំណឹងមុនត្រឹមត្រូវ៖ការរំលាយកិច្ចសន្យាដោយដោយកម្មករនិយោជិតស្របតាមច្បាប់

- ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)

# II. អំពីការបង្កើត ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## គ. កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC)

### ៣. អត្ថប្រយោជន៍ដែលទទួលបានក្រោយការរំលាយកិច្ចសន្យាការងារ UDC

ដោយសារកំហុសធ្ងន់របស់កម្មករនិយោជិត៖ការរំលាយកិច្ចសន្យាដោយដោយនិយោជកស្របតាមច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)

②

មិនមានហេតុផលសមរម្យ និងមានការជូនដំណឹងមុនត្រឹមត្រូវ៖

ការរំលាយកិច្ចសន្យាដោយដោយនិយោជកមិនស្របតាមច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)
- ❖ ប្រាក់បំណាច់អតីតភាពការងារ (មាត្រា៨៩ថ្មី)
- ❖ ប្រាក់សោហ៊ុយជំងឺចិត្ត (មាត្រា៩១ថ្មី)

# II. អំពីការបញ្ចប់ ការរំលាយ និងអត្ថប្រយោជន៍ក្រោយការរំលាយ

## គ. កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC)

### ៣. អត្ថប្រយោជន៍ដែលទទួលបានក្រោយការរំលាយកិច្ចសន្យាការងារ UDC

មិនមានហេតុផលសមរម្យ និងមិនមានការជូនដំណឹងមុនត្រឹមត្រូវ៖ ការរំលាយកិច្ចសន្យាដោយនិយោជកមិនស្របតាមច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាច់ជួសការឱ្យដំណឹងមុន (មាត្រា៧៥ និង មាត្រា៧៧)
- ❖ ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)
- ❖ ប្រាក់បំណាច់អតីតភាពការងារ (មាត្រា៨៩ថ្មី)
- ❖ ប្រាក់សោហ៊ុយជំងឺចិត្ត (មាត្រា៩១ថ្មី)

៣

មិនមានការជូនដំណឹងមុនត្រឹមត្រូវ៖ ការរំលាយកិច្ចសន្យាដោយដោយកម្មករនិយោជិតមិនស្របតាមច្បាប់

- ❖ ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ❖ ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និង មាត្រា១៦៧)

# សូមអរគុណ